# បសុព្យាបាល និងផលិតកម្មសត្វ
# ក្នុងព្រះរាជាណាចក្រកម្ពុជា

ខែវិច្ឆិកា ឆ្នាំ២០១០

អនុក្រុមស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម
នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC)

ទីស្តីការគណៈរដ្ឋមន្ត្រី

# មាតិកា

**ទំព័រ**

**I. សេចក្តីផ្តើម**..................................................................................១
**II. ស្ថានភាពបសុសត្វ**...........................................................................១
**ក. ប្រព័ន្ធផលិតកម្ម បសុសត្វ**................................................................១
១. ប្រព័ន្ធផលិតកម្មសម្រាប់បរិភោគផ្ទាល់ខ្លួន...............................១
២. ប្រព័ន្ធផលិតកម្មជំនួញ..............................................................២
**ខ. ការអភិវឌ្ឍធនធានសបសុសត្វ**.....................................................២
១. ការចិញ្ចឹមគោ.............................................................................៣
២. ការចិញ្ចឹមក្របី...........................................................................៤
៣. ការចិញ្ចឹមជ្រូក...........................................................................៤
៤. ការចិញ្ចឹមបក្សី..........................................................................៥
៥. ការចិញ្ចឹមពពែ..........................................................................៦
៦. ចំណាប់អារម្មណ៍លើការរើសពូជសត្វ............................. ......៦
**គ. សត្តឃាតដ្ឋាន និងការប្រើប្រាស់សាច់**.........................................៧
**ឃ. សកម្មភាពនាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វ**.........៩
១. រដ្ឋបាល......................................................................................៩
២. សកម្មភាព..................................................................................១០
ក. កសិដ្ឋានចិញ្ចឹមសត្វរបស់រដ្ឋ ..............................................១០
ខ. ចំការដំណាំសម្រាប់ជាចំណីសត្វ...........................................១០
៣. ឡចំហុយជីវឧស្ម័ន.....................................................................១០
៤. ការការពារសុខភាពសត្វ ការចាក់វ៉ាក់សាំង និងការព្យាបាល....១២
**III. ការប្រឈម និងដែនកំណត់**.............................................................១៤
**IV. ភាពលានុវត្តភាព**.............................................................................១៥
**V. អនុសាសន៍**........................................................................................១៦
**VI. សេចក្តីសន្និដ្ឋាន**........................ ...................................................១៦
**ឯកសារយោង**............................................................................ ..........១៧
**ការសំភាសន៍**............................................................................ .........១៧

## I. សេចក្តីផ្តើម

អនុវិស័យបសុសត្វ គឺជាផ្នែកពាក់ព័ន្ធមួយនៃប្រព័ន្ធផលិតកម្មកសិកម្ម នៅកម្ពុជា និងជាពិសេសទៅទៀតកំលាំង និងសក្តានុពលរបស់វាដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យកសិកម្មទាំងមូល។ អត្រារួមចំណែកនៃវិស័យកសិកម្មក្នុងផលិតផលក្នុងស្រុកសរុប បានធ្លាក់ចុះជាលំដាប់ចាប់ពីឆ្នាំ១៩៩៩មក លើកលែងតែពីរឆ្នាំចុងក្រោយដែលបង្ហាញពីការកើនឡើងរបស់វិស័យនេះ(តារាង១)។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ( 2005-2009 ) អនុវិស័យបសុសត្វបានរួមចំណែកក្នុងកំរិតជាង១៥%ជាប្រចាំទៅក្នុងវិស័យកសិកម្ម (តារាង១)។

**តារាងទី១: %នៃវិស័យកសិកម្មក្នុង GDP និង%នៃអនុវិស័យបសុសត្វក្នុងកសិកម្ម**

| ឆ្នាំ | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|---|---|---|---|---|
| %វិស័យកសិកម្ម ក្នុង ផសស | 41.5 | 37.8 | 36.2 | 33.3 | 31.5 | 32.0 | 30.7 | 30.1 | 29.7 | 32.8 | 33.5 |
| %អនុវិស័យបសុសត្វ ក្នុងកសិកម្ម | | | | | | | 15.4 | 15.8 | 15.6 | 15.5 | 15.3 |

**ប្រភព**: Adapted from MAFF Annual Report 2009 – 2010

បច្ចុប្បន្ន ប្រសិទ្ធភាពផលិតកម្មនៃអនុវិស័យបសុសត្វនៅមានកំរិតទាបដោយសារកង្វះខាតប្រព័ន្ធគាំទ្រនៃការត្រួតពិនិត្យជំងឺដែលមានប្រសិទ្ធភាព និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការផ្គត់ផ្គង់ចំណីសត្វ និងធាតុចូលដទៃទៀតនៅខ្សត់ខ្សោយ។ ស្ទើរតែគ្រប់ផលិតកម្មទាំងអស់នៃអនុវិស័យនេះដូចជាផលិតកម្មគោ ក្របី ជ្រូក និងបក្សី ប្រមូលផ្តុំនៅក្នុងដៃរបស់កសិករខ្នាតតូច គឺអ្នកដែលធ្វើកសិកម្មជាប្រចាំទុកសម្រាប់តែបរិភោគ។ពួកគាត់ប្រើប្រាស់សត្វគោ ក្របីសម្រាប់ជាកំលាំងអូសទាញក្នុងការធ្វើស្រែចំការ និងសម្រាប់ដឹកជញ្ជូនកសិផល។ ពួកគាត់នឹងសំលាប់សត្វទាំងនោះ ដើម្បីយកសាច់នៅពេលដែលពួកវាមិនអាចអូសទាញនង្គ័លបានតទៅទៀត។ សត្វជ្រូក និងសត្វបក្សីត្រូវបានចិញ្ចឹមឡើងសម្រាប់យកសាច់ និងសម្រាប់ប្រាក់ចំណូលបន្ថែមនៅពេលត្រូវការចាំបាច់។

## II. ស្ថានភាពបសុសត្វ

### ក. ប្រព័ន្ធផលិតកម្មបសុសត្វ

ប្រព័ន្ធផលិតកម្មបសុសត្វមានពីរបែប: ប្រព័ន្ធផលិតកម្មសម្រាប់បរិភោគផ្ទាល់ខ្លួន និងសម្រាប់ធ្វើជំនួញ។

#### ១. ប្រព័ន្ធផលិតកម្មសម្រាប់បរិភោគផ្ទាល់ខ្លួន

ក្នុងប្រព័ន្ធនេះ ជាទូទៅអនុវត្តដោយកសិករភាគច្រើន ដែលប្រើបសុសត្វជាកម្លាំងអូសទាញ និងមធ្យោបាយដឹកជញ្ជូន។ បសុសត្វផ្សេងទៀតដូចជា ជ្រូក និងបក្សី ក៏ត្រូវបានចិញ្ចឹម

ដើម្បីផ្តល់ជាសាច់ និងចំណូលបន្ថែម។ សត្វទាំងនោះ ត្រូវបានទុកបណ្តោយឲ្យដើររកចំណី ដោយខ្លួនឯង និងក្នុងកាលៈទេសៈខ្លះ គេឲ្យចំណីវាបន្ថែមដូចជាស្រូវ និងកន្ទក់។ ប្រជាជនជាង ៩០% មានគោ និងក្របីស្ថិតក្នុងប្រព័ន្ធនេះ។ ជាទូទៅ នៅតំបន់ជនបទ គ្រួសារនីមួយៗ មានគោឈ្មោល ឬក្របីឈ្មោលមួយគូសម្រាប់អូសទាញ និងគោញី ឬក្របីញីមួយ សម្រាប់បង្កាត់ពូជ។ គោឈ្មោលបីប្រភេទ ដែលកសិករមួយចំនួនធំចូលចិត្តចិញ្ចឹមគឺ គោខ្មែរ ហារីយ៉ាណា និងប្រាហម៉ាន និងក្របីពីរប្រភេទគឺ ក្របីភ្នំ និងក្របីក្តាម។ ជ្រូកដើតួរសំខាន់ក្នុងការសន្សំ ជាប្រភពនៃសេចក្តីត្រូវការប្រាក់បន្ទាន់ នៅពេលគ្រួសារមានវិបត្តិ និងរដូវបុណ្យទាន។ មាន់ និងទាត្រូវបានប្រើប្រាស់ជាទូទៅសម្រាប់ការបរិភោគផ្ទាល់ខ្លួន ។ ដូចក្នុងករណីជ្រូកដែរ មាន់ ទា ត្រូវបានចិញ្ចឹមដោយប្រើបច្ចេកទេស(extensive)មានន័យថាពួកវាត្រូវបានអនុញ្ញាតឲ្យដើរសេរីរកចំណីស៊ីដោយខ្លួនឯង។ គ្រួសារជនបទនីមួយៗជាទូទៅមានចិញ្ចឹមជ្រូកពី២ ទៅ៣ក្បាល មាន់ពី១០ ទៅ១៣ក្បាល និងទាពី៦ ទៅ១២ក្បាល។ ប្រហែលជា៣/៤នៃមាន់និងទាត្រូវបានផ្គត់ផ្គង់ដល់ទីផ្សារក្នុងស្រុក។

២. ប្រព័ន្ធផលិតកម្មជំនួញ

នេះជាប្រព័ន្ធបែបប្រពលវប្បកម្មដែលកសិករ ឬអ្នកជំនួញធ្វើការជ្រើសរើសប្រភេទពូជសត្វ ចំណីសត្វ និងប្រព័ន្ធចិញ្ចឹមសត្វសមរម្យ។ ប្រព័ន្ធនេះត្រូវបានចែកចេញជាពីរក្រុមៈ ប្រតិបត្តិការគ្រួសារ(ទ្រង់ទ្រាយតូច) និងប្រតិបត្តិការទ្រង់ទ្រាយធំ។ ប្រតិបត្តិការគ្រួសារមានចិញ្ចឹមជ្រូកពី៥០ ទៅ១០០ក្បាល និងមាន់ពី៥០០ ទៅ១០០០ក្បាល។ ប្រតិបត្តិការជំនួញខ្នាតមធ្យមមានជ្រូកពី១០០ ទៅ៥០០ក្បាល និងមាន់ពី១០០០ ទៅ៥០០០ក្បាល។ ប្រតិបត្តិការជំនួញខ្នាតធំមានជ្រូកលើសពី៥០០ក្បាល និងមាន់លើសពី៥០០០ក្បាល។

នៅក្នុងប្រព័ន្ធផលិតកម្មជំនួញ គោលបំណងរបស់កសិករ គឺផលិតសត្វទុកសម្រាប់បង្កាត់ពូជ និងសម្រាប់យកសាច់។ មុនឆ្នាំ២០០២ មិនទាន់មានប្រព័ន្ធផលិតកម្មគោ ក្របីខ្នាតធំនៅឡើយ ប៉ុន្តែសម្រាប់សត្វជ្រូកមានកសិករខ្នាតមធ្យមមួយចំនួនបាននាំចូលជ្រូកបាមកពីប្រទេសថៃ វៀតណាម តៃវ៉ាន់។ ប្រភេទជ្រូកដែលពេញនិយមជាងគេមាន Landrace, Duroc, and Yorkshire ។ សម្រាប់បក្សីវិញ មានកសិករខ្នាតមធ្យមរាប់ពាន់គ្រួសារ ជាអ្នកផ្គត់ផ្គង់ស៊ុត និងសាច់សម្រាប់ទីផ្សារក្នុងស្រុក។

**ខ. ការអភិវឌ្ឍធនធានបសុសត្វ**

ជាទូទៅ ផលិតកម្មបសុសត្វ និងបក្សីទទួលបានការអភិវឌ្ឍជាវិជ្ជមានទាំងបរិមាណ ទាំងបច្ចេកទេស។ ទាំងសាច់ ទាំងស៊ុតត្រូវបានផលិតយ៉ាងគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុក និងគោ ក្របីរស់មួយចំនួនត្រូវបាននាំចេញ។ ពីឆ្នាំ២០០៤ ដល់២០០៩ពពួក

សត្វគោបានកើនឡើង១៧.៥% ក្របី១៣.៧% បក្សី៤៤.៣%(តារាង២)។ ផ្ទុយពីនេះ ពពួកជ្រូកបានធ្លាក់ចុះ១២.២% ដោយសារលំហូរចូលនៃជ្រូករស់យ៉ាងអានាធិបតេយ្យពីប្រទេសជិតខាង និងថ្លៃដើមខ្ពស់នៃផលិតកម្មក្នុងប្រទេស។

តារាង២: ផលិតកម្មគោ ក្របី ជ្រូក និងបក្សី(១០០០ក្បាល)

| ប្រភេទបសុសត្វ | ឆ្នាំ | | | | | |
|---|---|---|---|---|---|---|
| | 2004 | 2005 | 2006 | 2007 | 2008 | 2009 |
| គោ | 3.04 | 3.18 | 3.35 | 3.37 | 3.46 | 3.58 |
| ក្របី | 0.65 | 0.68 | 0.72 | 0.77 | 0.75 | 0.74 |
| ជ្រូក | 2.43 | 2.69 | 2.74 | 2.39 | 2.22 | 2.13 |
| បក្សី | 1.40 | 1.51 | 1.51 | 1.58 | 1.69 | 2.02 |
| សត្វអូសទាញ | N/A | N/A | 1.75 | 1.75 | 1.74 | 1.87 |

N/A = បានព្យាករមានជិត១.៧លានក្បាល ដោយផ្អែកលើទិន្នន័យចាស់

ប្រភព: Adapted from:

- MAFF Annual report 2009 – 2010
- Directorate of Livestock & Poultry Annual Report 2009
- Statistical Yearbook of Cambodia 2008.

### ១. ការចិញ្ចឹមគោ

សត្វគោនៅកម្ពុជាត្រូវបានរក្សាទុកជាពិសេសក្នុងគោលបំណងអូសទាញនង្គ័ល និងយកសាច់។ ជាមធ្យម គោឈ្មោល១គូ ឬក្របីអាចភ្ជួរបានបីហិចតាក្នុង១ឆ្នាំ។ ខេត្តដែលសម្បូណ៌គោច្រើនជាងគេ គឺកំពង់ចាម កំពង់ស្ពឺ តាកែវ ព្រៃវែង និងសៀមរាប។ នៅតំបន់ភាគច្រើន ចំណីអាហារមិនមានគ្រប់គ្រាន់ក្នុងរយៈពេលវែងក្នុងមួយឆ្នាំៗ ពីព្រោះមួយភាគធំនៃផ្ទៃដីស្ថិតក្រោមផលិតកម្មស្រូវ និងលិចទឹក និងក្រោយពេលការប្រមូលផលស្រូវ គឺនៅពេលដែលសត្វអាចដើររកស៊ីដោយសេរីបាន ស្មៅក៏មានតិចតួចដែរក្នុងកំឡុងពេលរដូវប្រាំង។ ដូច្នេះក្នុងមួយឆ្នាំៗសត្វត្រូវផ្អែកលើចំបើង ជាចំណី។ នៅតំបន់ដែលសត្វទាំងនោះលូតលាស់បានល្អ គោញីចាស់អាចឡើងទម្ងន់ដល់២៥០គីឡូក្រាម និងគោឈ្មោលអាចប្រហែលពី៣០០ ដល់៣៥០ គីឡូក្រាម។ ទាំងការខ្វះខាតចំណី ទាំងជំងឺបានកំរិតផលិតផលរបស់សត្វនេះ។ ជំងឺសត្វគោនៅកម្ពុជាមាន:

- ជំងឺសារទឹក ( Haemorrhagic septicemia)
- ជំងឺអុតក្តាម (FMD)
- ជំងឺបូសខ្យល់(Black leg)
- ជំងឺឈាមខ្មៅ (Anthrax)

- ជំងឺផ្សេងៗដែលបង្កឡើងដោយបរាសិតដូចជាៈ
    - Fascioliasis
    - Toxocariasis
    - Trypanosomiasis, etc...

គោញីជាទូទៅចាប់ផ្តើមមានកូនលើកទី១ក្នុងវ័យពី២.៥ ទៅ៣ឆ្នាំ និងបង្កើតកូនបានមួយក្នុងរយៈពេល១.៥ឆ្នាំម្តង។ អត្រាស្លាប់មានប្រហែលកំរិត៦% និងពី១០ទៅ១២% រៀងគ្នាសម្រាប់គោពេញវ័យ និងគោក្មេង។ គោញី ត្រូវបានគេសម្លាប់យកសាច់នៅវ័យពី១០ទៅ១២ឆ្នាំដែលក្នុងអំឡុងពេលនេះ ពួកវាបានបង្កើតកូនពី៤ទៅ៥ដែលក្នុងនោះ គោ៣អាចរស់នៅរហូតដល់ចាស់។ គោដែលអូសទាញជាទូទៅត្រូវបានលក់ឲ្យគេកាប់យកសាច់ក្នុងវ័យជិត១២ឆ្នាំ។ គោដែលនៅវ័យក្មេងត្រូវបានលក់ឲ្យពាណិជ្ជករសម្រាប់ផ្គត់ផ្គង់ទីផ្សារ ថៃនិងវៀតណាម។

### ២. ការចិញ្ចឹមក្របី

នៅកម្ពុជា ក្របីមានចំនួនតិចជាងគោ ក៏ប៉ុន្តែសត្វក្របីដើរតួយ៉ាងសំខាន់ក្នុងប្រព័ន្ធធ្វើស្រែចំការ ជាពិសេសសម្រាប់ការដាំដុះនៅតំបន់សើម និងតំបន់ដីឥដ្ឋ។ សត្វក្របីមានភាគច្រើននៅខេត្តកំពង់ចាម ស្វាយរៀង និងព្រៃវែង ដែលផ្គត់ផ្គង់សត្វអូសទាញក្នុងបរិមាណពី៣០%ទៅ៥០%។ ក្របីទាំងនេះគឺជាប្រភេទដែលចូលចិត្តភក់ និងជាទូទៅរីកធំធាត់បានល្អ និងដែលមានទម្ងន់ខ្លួនពី៣៥០ទៅ៥០០គីឡូក្រាម សម្រាប់ក្របីឈ្មោលវ័យចំណាស់ និងមានពី៣០០ទៅ៣៥០គីឡូក្រាម សម្រាប់ក្របីញី។ នេះជាការអនុវត្តទូទៅដែលគេប្រើក្របីទាំងញីទាំងឈ្មោលឲ្យអូសទាញ។ ក្របីតែងផ្តល់កំណើតកូនទី១ក្នុងវ័យពី៣ ទៅ៥ឆ្នាំ។ ក្របីអាចផ្តល់កូនមួយក្នុងរយៈពេល២០ខែម្តង។ ក្របីឈ្មោលជាទូទៅត្រូវបានគេសំលាប់ពេលគម្រប់១២ឆ្នាំឯក្របីញីពេលគម្រប់១១ឆ្នាំ។ ថ្វីត្បិតតែក្របីហាក់ដូចជាមានសុខភាពមាំទាំក្រោមលក្ខខ័ណ្ឌចំណីអាហារគ្រប់គ្រាន់ តែពួកវាភាគច្រើនងាយទទួលរងជំងឺសារទឹក និងអត្រាស្លាប់របស់កូនក្របីមានកំរិតខ្ពស់ជាងកូនគោ។ នេះប្រហែលមកពីលទ្ធផលនៃភាពងាយទទួលរងបរាសិតក្នុងខ្លួន ជាពិសេសបរាសិត (Neoascaris spp)។

### ៣. ការចិញ្ចឹមជ្រូក

សត្វជ្រូកដើរតួសំខាន់ណាស់នៅក្នុងជីវិតរស់នៅនៃប្រជាជនកម្ពុជា។ សាច់ជ្រូក ជាសាច់ដែលគេចូលចិត្តទាំងនៅជនបទទាំងនៅទីប្រជុំជន។ ជ្រូកគឺជាសមាសភាពយ៉ាងសំខាន់ក្នុងការសន្សំនៅតំបន់ជនបទ និងបង្កើនទ្រព្យសម្បត្តិ។ ឧស្សាហកម្មជ្រូកខ្នាតតូច ជាទូទៅមានជ្រូកញី១ ឬ ២ ក្បាល និងជ្រូកយកសាច់១ក្បាល ប៉ុន្តែមានការចិញ្ចឹមពិសេសសម្រាប់តែបង្កាត់កូន យកសាច់ និងកូនជ្រូកសម្រាប់ឲ្យចំណីយកសាច់។ ជាមធ្យមមេជ្រូក១បង្កើតកូន

បានចំនួន៨ និងក្នុងចំណោមនោះ ៦អាចនៅរស់។ កូនជ្រូកត្រូវបានលក់ទៅឲ្យកសិករដែលនៅក្នុងភូមិជាមួយ ក៏ប៉ុន្តែក៏មាននិន្នាការខ្លាំងលក់ទៅឲ្យកសិករដែលនៅខេត្តជិតៗផងដែរ។ ពាណិជ្ជករខ្នាតតូចទិញកូនជ្រូកទើបផ្តាច់ដោះនៅទីផ្សារពី៣ទៅ៤ក្បាល ហើយដាក់ពួកវាក្នុងទ្រុង និងដឹកតាមកង់ ម៉ូតូយកទៅលក់ដល់ដៃកសិករតែម្តងក្នុងចំងាយប្រហែល៥០គីឡូម៉ែត។ ខេត្តដែលចិញ្ចឹមជ្រូកច្រើនជាងគេមាន ខេត្តព្រៃវែង តាកែវ កំពង់ចាម កំពង់ស្ពឺនិងស្វាយរៀង។ ជ្រូកតែងតែត្រូវបានគេសំលាប់ក្នុងវ័យពី៩ទៅ១២ខែ និងអាចមានទម្ងន់ពី៦០ទៅ៧០គីឡូក្រាមរស់។ បច្ចុប្បន្នមានបរិមាណជ្រូកជាច្រើនត្រូវបាននាំចូលពីប្រទេសវៀតណាម និងថៃដើម្បីផ្គត់ផ្គង់ ជាពិសេសទីផ្សារភ្នំពេញ ដែលជ្រូកទាំងនោះមានទម្ងន់ពី៨០ទៅ៩០គីឡូក្រាម។ ជំងឺទូទៅដែលជ្រូកតែងជួបប្រទះមាន: Pasteurellosis, Salmonellosis, Swine Fever, E. Coli, Swine Erycipelis. ជំងឺផ្សេងទៀតដែលបង្កើតឡើងដោយបរាសិតមាន: Ascariasis, Sarcotosis, Cysticercosis។

### ៤. ការចិញ្ចឹមបក្សី

ផលិតកម្មបក្សីនៅកម្ពុជាមានលក្ខណៈជាឧស្សាហកម្មខ្នាតតូចណាស់ និងផលិតកម្មភាគច្រើនចេញពីប្រតិបត្តិការផ្ទាល់នៅផ្ទះដែលមានបក្សីតែមួយចំនួនប៉ុណ្ណោះ គឺដូចជាសកម្មភាពបន្ទាប់បន្សំក្នុងកំរិតភូមិ ស្រុក។ គ្រួសារភាគច្រើនចិញ្ចឹមមាន់ពី១០ ទៅ១៣ក្បាល។ មាន់ស្រុកមានរូបរាងបែបមាន់ព្រៃ គឺមានជើង និងកវែង និងមានដងខ្លួនស្រាល។ ពួកវាអាចផ្តល់ស៊ុតពី៦០ទៅ៧០ក្នុង១ឆ្នាំ ហើយគេចិញ្ចឹមពួកវាក្នុងគោលបំណងចិញ្ចឹមជីវិត គឺសម្រាប់ប្រើប្រាស់ជាសាច់ផង និងស៊ុតផង។ ប៉ុន្តែនៅមានអ្នកជំនួញខ្នាតតូចមួយចំនួននៅទីប្រជុំជនដែលមានបក្សីពី១០០ទៅ៥០០ក្បាលដែលមានលក្ខណៈជាប្រតិបត្តិការគ្រួសារតូចៗ និងចាប់ពី៥០០០ក្បាលឡើងទៅប្រតិបត្តិដោយអ្នកជំនួញខ្នាតធំពេញលេញ។ ផលិតករទាំងនេះជាទូទៅ លាយចំណីសត្វដោយខ្លួនឯងដោយប្រើកន្ទក់ ចុងអង្ករ ពោត ត្រី ម្សៅ ផ្គួបផ្សំនឹងចំណីនាំចូលផងដែរ។ មាន់សដែលនាំចូលពីវៀតណាម និងថៃតែងតែត្រូវបានរក្សាទុកឲ្យក្រាបពង២ជុំសិន មុនពេលលក់វា។ ផលិតកម្មស៊ុតបក្សីមានជិត១៧០ស៊ុតក្នុងរយៈពេលក្រាបពង។ ខេត្តដែលផលិតបក្សីច្រើនជាងគេមានព្រៃវែង តាកែវ កំពង់ចាម បាត់ដំបង សៀមរាប កណ្តាល និងកំពត។

សត្វទាត្រូវបានគេចិញ្ចឹមសម្រាប់ផលិតកម្មស៊ុត។ មានគ្រួសារមួយចំនួនតិចទេដែលចិញ្ចឹមទា ហើយអ្នកទាំងនោះជាទូទៅមានទាពី៦ទៅ១២ក្បាល។ ផលិតករដែលធ្វើឯកទេស-កម្មខាងផលិតពងមានទាពី១០០ទៅ២០០ក្បាល។ ប្រតិបត្តិករមួយចំនួនផលិតពងទាកូនពី១៥ទៅ១៨ថ្ងៃសំរាប់លក់ ហើយមួយចំនួនទៀតលក់ស៊ុតស្រស់តែម្តង។ ទាឈ្មោលត្រូវបានចិញ្ចឹម

ឲ្យធំធាត់ទុកសម្រាប់លក់ ចំណែកឯទាញីត្រូវបានលក់ក្នុងទីផ្សារក្នុងតម្លៃជិត៦៥%នៃតម្លៃមាន់។ ទាភាគច្រើនត្រូវបានលែងនៅតំបន់មានទឹកក្នុងរយៈពេលថ្ងៃ និងដាក់ក្នុងជំរកនៅពេលយប់។ គេចិញ្ចឹមទាដោយឲ្យចំណីចំរុះផ្សេងៗដូចជាកន្ទក់ ពោត ស្រូវ និងកូនត្រីដែលគេចោល។ សត្វទាជាទូទៅត្រូវបានគេរក្សាទុកឲ្យវាក្រាបពងក្នុងរយៈពេល២រដូវដែលក្នុងរយៈពេលនោះវាផលិតបាន១៨០ស៊ុតក្នុងរដូវទី១ និង១៤០ស៊ុតក្នុងរដូវទី២។

ជំងឺទូទៅសម្រាប់បក្សីមានៈ ជំងឺ New castle disease អាសន្នរោគ រាក់ទា ជំងឺមានព្រូន។ នៅឆ្នាំថ្មីៗនេះ មានការរីកសាយភាយជំងឺផ្តាសាយបក្សី។ ជាសំណាងល្អនៅកម្ពុជាមិនសូវមានឆ្លងជំងឺនេះធំដុំទេ ដោយសារការអន្តរាគមន៍យ៉ាងឆាប់រហ័សរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ៥. ការចិញ្ចឹមពពែ

ពពែជាធម្មតាត្រូវបានចិញ្ចឹមក្នុងបរិមាណតិចតួចណាស់ដោយសហគមន៍ម៉ូស្លីមមួយចំនួន ភាគច្រើននៅតំបន់ជាយក្រុង។ គេចិញ្ចឹមវាភាគច្រើនសម្រាប់យកសាច់ ឯភាគតិចទុកសម្រាប់យកទឹកដោះ។ ជនជាតិខ្មែរភាគច្រើនមិនចូលចិត្តហូបសាច់ពពែទេ ប៉ុន្តែថ្មីៗនេះមានការផ្លាស់ប្តូររសជាតិមួយចំនួន ពីព្រោះសង្កេតឃើញនៅភោជនីយដ្ឋានមួយចំនួនក្នុងទីក្រុងមានបំរើស៊ុប និងមុខម្ហូបឆ្ងាញ់ៗផ្សេងទៀតធ្វើពីសាច់ពពែ។

### ៦. ចំណាប់អារម្មណ៍លើការរើសពូជសត្វ

ដើម្បីធ្វើឲ្យមានការរីកចំរើនក្នុងវិស័យផលិតកម្មសត្វ គេត្រូវពឹងផ្អែកជាបឋមលើការរើសពូជសត្វល្អៗដែលមានកាពីតាល់សេណេទិចខ្ពស់ ហើយអាចសម្រួល និងធន់នឹងអាកាសធាតុស្រុកយើងផង។ យោងតាមគំនិតនេះ នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វបានបង្កើតស្ថានីយផ្សព្វផ្សាយពូជសត្វពីរួចមកហើយ គឺស្ថានីយចិញ្ចឹមជ្រូកពូជកម្ពុជា-ចិននៅកប់ស្រូវ និងស្ថានីយបង្កាត់ពូជគោនៅភ្នំតាម៉ៅ។ ក្រៅពីនេះនាយកដ្ឋានបានសហការណ៍ជាមួយគម្រោង និងដៃគូអភិវឌ្ឍន៍មួយចំនួនទៀតដូចជាអង្គការ(FAO) អនុវត្តគម្រោងចិញ្ចឹមសត្វកម្ពុជា-សហគមន៍អ៊ឺរុប។ គម្រោងនេះគាំទ្រលើការចិញ្ចឹមសត្វ បង្ហាញការបង្កាត់ពូជសត្វតាមបែបសិប្បនិម្មិតរបស់សត្វគោ និងជ្រូក។

ចំពោះការចិញ្ចឹមមាន់ដើម្បីយកសាច់ និងស៊ុត ជាលក្ខណៈខ្នាតមធ្យម និងធំ មានក្រុមហ៊ុនឯកជនជាច្រើនបានអនុវត្តរួចមកហើយ ដោយនាំយកពូជសត្វមាន់សពីប្រទេសវៀតណាម និងថៃមក។

បើទោះជាមានការប្រឹងប្រែងយ៉ាងនេះក៏ដោយពីសំណាក់នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វ គេត្រូវជំរុញឲ្យបង្កើតបន្ថែមទៀតនូវស្ថានីយស្រាវជ្រាវសេណេទិចសត្វគោ

ក្របី ជ្រូក និងបក្សី ព្រោះស្ថានីយទាំងនេះ នឹងក្លាយទៅជាកន្លែងសម្រាប់ពិសោធន៍ស្រាវជ្រាវពូជសត្វ ការជ្រើសរើសពូជ មជ្ឈមណ្ឌលស្រាវជ្រាវជំងឺសត្វ ចំណីផ្សំសត្វ ផ្សព្វផ្សាយ និងជាមជ្ឈមណ្ឌលបណ្តុះបណ្តាលប្រជាពលរដ្ឋផងដែរ។

### គ. សត្តឃាតដ្ឋាន និងការប្រើប្រាស់សាច់

ដើម្បីធានាគុណភាពសាច់ និងគាំពារសុខភាពសាធារណៈ នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វ មានវិធានការមួយចំនួនដូចខាងក្រោម៖

– ពង្រឹងអនាម័យទូទៅ នៃសត្តឃាតដ្ឋាន

–ពង្រឹងអនាម័យក្នុងការដឹកនាំសាច់

– អប់រំភាគីគ្រប់កំរិត ដែលពាក់ព័ន្ធនឹងផលិតកម្ម និងការកែច្នៃសាច់ ព្រមទាំងអ្នកលក់សាច់

– ពង្រឹងការគោរពនិយាម និងបទបញ្ញត្តិផ្សេងៗ

ក្នុងទូទាំងប្រទេសកម្ពុជា នាឆ្នាំ២០១០ មានសត្តឃាតដ្ឋានចំនួន ៨៥ ដែលក្នុងនោះ ៦ ជាប្រភេទ “ ក” ដែលមានទំហំរាងធំ និងទំនើប។ ឯ១១០ទៀត ជាប្រភេទ “ ខ” ដែលមានទំហំរាងតូច និងមិនសូវទំនើប និងចំនួន ៦៩ទៀតជារបស់គ្រួសារ។ សត្តឃាតដ្ឋានមួយចំនួនមានអាជ្ញាប័ណ្ណជាផ្លូវការ និងមួយចំនួនទៀតពុំទាន់មាននៅឡើយ។

ក្នុងឆ្នាំ ២០០៧ ប្រជាជនកម្ពុជាម្នាក់ៗ ប្រើប្រាស់ជាមធ្យមប្រហែល ៥.៨គក្រសាច់គោ និងក្របី ៨.២១គក្រសាច់ជ្រូក និង១.៩គក្រសាច់មាន់ និងទា ក្នុង១ឆ្នាំ ដែលជាកំរិតមួយទាប បើប្រៀបធៀបនឹងប្រទេសជិតខាង ដែលតួលេខសាច់មាន់តែមួយមុខលើស ២០គក្រក្នុងមនុស្សម្នាក់ទៅហើយ។ តែគេគួរទទួលស្គាល់ថា ប្រជាពលរដ្ឋចូលចិត្តទទួលទានសាច់ត្រី

**តារាង ៣: ប្រភេទផលិតផល និងចំនួនកសិដ្ឋានផលិតកម្មសត្វ**

| ប្រភេទផលិតផល | ចំនួនកសិដ្ឋាន | | ចំនួនសត្វ(ក្បាល) | |
|---|---|---|---|---|
| | 2008 | 2009 | 2008 | 2009 |
| មាន់ (សម្រាប់យកស៊ុត) | 45 | 244 | 218,750 | 533,071 |
| មាន់ (សម្រាប់យកសាច់) | 237 | 170 | 1,914,824 | 782,516 |
| ទា (សម្រាប់យកស៊ុត) | N/A | 317 | N/A | 270,685 |
| ទា (សម្រាប់យកសាច់) | 2,433 | 1,571 | 1,965,135 | 1,552,999 |
| ជ្រូក | 1,814 | 1,367 | 247,136 | 98,291 |
| គោក្របី | 57 | 52 | 6,725 | 6,453 |
| ពពែ | | 1 | | 180 |
| សរុប | **4,586** | **3,722** | **4,352,570** | **3,244,195** |

Source: MAFF Annual Report 2009

ជាងសត្វដទៃទៀត។ ប្រជាពលរដ្ឋខ្មែរទទួលទានសាច់ត្រីប្រហែល២៥គីឡូក្រាមម្នាក់ៗក្នុង១ឆ្នាំ។ ភាគច្រើនសាច់ដែលប្រើប្រាស់ ត្រូវបានផ្គត់ផ្គង់ដោយកសិដ្ឋានក្នុងស្រុក និងបំពេញបន្ថែមដោយការនាំចូលពីវៀតណាម និងថៃ (តារាង ៣ខាងលើ)។

ស្ថិតិនាំចូល និងនាំចេញសត្វទៅប្រទេសជិតខាង គឺពិបាករកណាស់។ បើសិនជារកបាន ក៏ពិបាកទុកចិត្តលើតួលេខនោះដែរ ពីព្រោះការនាំចេញ–នាំចូល ភាគច្រើនតាមច្រករបៀង។ ក្នុងឆ្នាំ ២០០៩ នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វមានរបាយការណ៍ថា គោក្របី ៩៣០៦៧ ក្បាល ជ្រូក ៦៤០ ៥៨៩ ក្បាល ត្រូវបានសម្លាប់។ តារាង ៤ ខាងក្រោមជារបាយការណ៍របស់នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វ។

**តារាង ៤: ការនាំចូល និងនាំចេញសត្វ**

| ឆ្នាំ | 2008 | 2009 |
|---|---|---|
| **នាំចេញ** | | |
| គោ និងក្របី | 9,120 heads | 28,386 heads |
| ស្វារ | 10,740 heads | 12,830 heads |
| ស្បែកគោក្របី | 1,244 tons | 1,437 tons |
| ចំណីផ្អែ | | 38,839 kg |
| **នាំចូល** | | |
| គោពីប្រទេសថៃ | 51,550 heads | 183,255 heads |
| គោបា | N/A | 50 heads |
| សាច់គោ | N/A | 13,478 kg |
| ជ្រូកសម្រាប់យកសាច់ | 43,500 heads | 335,690 heads |
| កូនជ្រូកសម្រាប់ចិញ្ចឹម | 12,500 heads | 1,180 heads |
| ជ្រូកមេសម្រាប់បង្កាត់ | 10,740 heads | 1,020 heads |
| សាច់ពពែ | N/A | 2,787 kg |

Source: MAFF Annual Report 2009, 2010

ផលប្រយោជន៍ពីការធ្វើជំនួញសត្វឆ្លងដែន រួមមានការធ្វើឲ្យថ្លៃទីផ្សារមានលំនឹង និងការពង្រីកទីផ្សារ ព្រមទាំងធ្វើឲ្យមានការរីកចំរើនខាងវិស័យបច្ចេកទេសចំណីសត្វ និងការបង្កាត់ពូជផងដែរ។ ជាមួយគ្នានេះ ការធ្វើជំនួញសត្វឆ្លងដែន អាចនាំឲ្យមានការឆ្លងជំងឺមានកំរិតខ្ពស់ដែរ។ គេគួរបង្កើតឲ្យមានជាការចាំបាច់នូវវិធានការ ដើម្បីការពារប្រឆាំងនឹងការរាតត្បាតនៃជំងឺសត្វទាំងនោះ។

តាមការស្រាវជ្រាវរបស់ CDRI ការនាំគោបង្កាត់ពូជចូលស្រុកខ្មែរពីប្រទេសថៃ ត្រូវឆ្លងកាត់ការឆែកឆេ១៥កន្លែង ត្រូវការពេលវេលា២ថ្ងៃ ហើយចាយសោហុយផ្លូវការ និងក្រៅផ្លូវការអស់៧០ដុល្លារអាមេរិចក្នុងសត្វ១ក្បាល ដើម្បីយកមកដល់ខេត្តកំពង់ចាម ហើយដែល

ឈ្មួញអាចលក់បានក្នុងថ្លៃពី១២០០ដល់១៥០០ដុល្លារអាមេរិក។ ឈ្មួញតូចតាចនៅតាមទល់ដែនខ្មែរ-វៀតណាម ដែលនាំគោចេញពី២ទៅ៦ក្បាល ត្រូវចំណាយ១ម៉ឺនរៀលក្នុង១ក្បាល ដើម្បីឆ្លងឃុំ ហើយ៣ម៉ឺន៥ពាន់រៀលទៀត ដើម្បីឆ្លងដែន។ ឈ្មួញធំៗនាំគោចេញតាមឡានដឹកពី៣០ទៅ៣៥ក្បាល ដោយបានបង់ប្រាក់៥០ម៉ឺនរៀលក្នុង១ក្បាល។ ជំនួញនាំសត្វចេញទៅប្រទេសវៀតណាម បានប្រព្រឹត្តទៅជារៀងរាល់ពេល លើកលែងតែនៅរដូវក្តៅខ្លាំងពេក។ គោ ក្របីដែលនាំចេញទៅប្រទេសវៀតណាម ត្រូវឈ្មួញទិញមកពីខេត្តបាត់ដំបង កំពង់ធំ ព្រះវិហារ ពោធិសត្វ បន្ទាយមានជ័យ និងប្រទេសថៃ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ឈ្មួញបាននាំចូលជ្រូកបង្កាត់ពូជពីប្រទេសថៃ។ ឯជ្រូកដើម្បីយកសាច់ ត្រូវឈ្មួញនាំចូលមកពីប្រទេសវៀតណាមដើម្បីផ្គត់ផ្គង់ឲ្យទីផ្សារក្រុងភ្នំពេញ។ អ្នកចិញ្ចឹមជ្រូកខ្មែរតែងតែត្អូញត្អែរពីការនាំចូលជ្រូកមកពីវៀតណាម ព្រោះតម្លៃថោកជាងជ្រូកក្នុងស្រុក។

## ឃ. សកម្មភាពនាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វ

### ១. រដ្ឋបាល

នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វមានការទទួលខុសត្រូវដូចខាងក្រោមៈ

- រៀបចំគោលនយោបាយ និងផែនការសម្រាប់អភិវឌ្ឍសុខភាព និងផលិតកម្មសត្វ
- ជួយសម្របសម្រួល អាជ្ញាធរ និងផលិតករ
- ចែកចាយព័ត៌មានបច្ចេកទេស និងធុរកិច្ច ដល់ផលិតករ
- ត្រួតពិនិត្យសុខភាព និងមានវិធានការសមស្របដើម្បីការពារសត្វ
- ជំរុញការអនុវត្តច្បាប់ និងបញ្ញត្តិផ្សេងៗ ដែលទាក់ទងនឹងការនាំចូល នាំចេញសត្វ និងអនាម័យសត្តឃាតដ្ឋាន ដើម្បីធានាសុខភាពសាធារណៈ។

ដើម្បីសម្រេចបានគោលដៅខាងលើ នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វមានបុគ្គលិកចំនួន ៩៥៦នាក់: ៣០៨នាក់ ប្រចាំការនៅទីស្នាក់ការនាយកដ្ឋាន និង ៦៤៨នាក់ធ្វើការនៅតាមខេត្ត (តារាង ៥)។

**តារាង ៥: ស្ថិតិបុគ្គលិកនៅនាយកដ្ឋានសុខភាព និងផលិតកម្មសត្វ ២០០៨ និង ២០០៩**

| កំរិតអប់រំ | នៅនាយកដ្ឋាន | | នៅតាមខេត្ត | | សរុប | |
|---|---|---|---|---|---|---|
| | 2008 | 2009 | 2008 | 2009 | **2008** | **2009** |
| បណ្ឌិត | 6 | 7 | 0 | 0 | **6** | **7** |
| អនុបណ្ឌិត | 9 | 10 | 6 | 14 | **15** | **24** |
| បរិញ្ញាបត្រ | 125 | 118 | 110 | 185 | **235** | **303** |
| បរិញ្ញាបត្ររង | 92 | 89 | 163 | 174 | **255** | **263** |
| អ្នកបច្ចេកទេសកំរិតទាប | 88 | 84 | 396 | 275 | **484** | **359** |
| សរុប | **320** | **308** | **675** | **648** | **995** | **956** |

Source: Department of Animal Health and Production Annual Report 2009

ក្រៅពីនោះ មានអ្នកបច្ចេកទេសពេទ្យសត្វចំនួន ១៣ ២៥០នាក់ ត្រូវបានបណ្តុះបណ្តាល និងផ្តល់វិញ្ញាបនបត្រ នៅមូលដ្ឋានផ្ទាល់តែម្តង។ អ្នកទាំងនេះផ្តល់សេវាកម្ម និងទទួលកម្រៃពីអ្នកចិញ្ចឹមសត្វផ្ទាល់ នៅតាមភូមិ ឃុំ និងស្រុក។ ពួកគេក៏បម្រើជាអ្នកផ្តល់ព័ត៌មាន ដល់នាយកដ្ឋាន នៅពេលបានបញ្ហាទាក់ទងនឹងសុខភាព និងជំងឺសត្វ។ ហើយពួកគេមាននាទីសំខាន់ ជាអ្នកប្រមែប្រមូលស្ថិតិសត្វផ្តល់ឲ្យនាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វផងដែរ។ យ៉ាងហោចណាស់មានអង្គការមិនមែនរដ្ឋាភិបាលប្រហែល៣០ បានចូលរួមជួយបង្ហាត់ហ្វឹកហ្វឺនអ្នកបច្ចេកទេសពេទ្យសត្វភូមិទាំងនោះ។

**២. សកម្មភាព**

នាយកដ្ឋានបានធ្វើសកម្មភាពជាច្រើន ដូចជា ការស្រាវជ្រាវ បណ្តុះបណ្តាលបំពាក់បំប៉នបន្ថែម ការចែកចាយពត៌មាន ការត្រួតពិនិត្យសុខភាព ការចាក់វ៉ាក់សាំង និង ព្យាបាលសត្វមានជំងឺ។ សកម្មភាពទាំងនេះ ទទួលហិរញ្ញបទានយ៉ាងតិចតួច។

**ក. កសិដ្ឋានចិញ្ចឹមសត្វរបស់រដ្ឋ**

–ជ្រូក: ជាមួយនឹងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីប្រទេសចិន កសិដ្ឋានចិញ្ចឹមជ្រូកមួយត្រូវបានបង្កើតឡើង។ នាខែមករា ឆ្នាំ២០០៩ កសិដ្ឋានផ្ទុក ជ្រូកមេចំនួន ១៥០ក្បាល ជ្រូកបា ២៣ក្បាល និងកូនជ្រូក ១៤៧ក្បាល។ កសិដ្ឋាននេះបានចែកចាយ ពូជជ្រូកចំនួន៨០ក្បាល ទៅកាន់កសិករចំនួន ១០ខេត្ត និងលក់ ៤៧ក្បាលឲ្យកសិករក្នុងតំបន់សម្រាប់ការបង្កាត់ពូជ។

–គោ: កសិដ្ឋានចិញ្ចឹមគោត្រូវបានបង្កើតនៅភ្នំតាម៉ៅ ក្នុងគោលបំណងពង្រីកការចិញ្ចឹម និងពូជនៅទីនេះ។ បច្ចុប្បន្ន កសិដ្ឋាននេះផ្ទុក គោឈ្មោល ៤៣ក្បាល និងគោញី ១៦១ក្បាល។ កសិដ្ឋានបានលក់ពូជចំនួន ៣ក្បាលសម្រាប់បង្កាត់។ ទន្ទឹមនឹងនេះ កសិដ្ឋានក៏ជំរុញកសិករដាំពូជស្មៅ (King Grass) សម្រាប់ជាចំណីសត្វ។

**ខ. ចំការដំណាំសម្រាប់ជាចំណីសត្វ**

នាយកដ្ឋានបានរៀបចំការស្រាវជ្រាវយ៉ាងសកម្មលើ ដំណាំសម្រាប់ជាចំណីសត្វ និងចែកចាយលទ្ធផលដល់កសិករ ដើម្បីអនុវត្ត។ ពូជដំណាំដែលនាយកដ្ឋានជំរុញឲ្យកសិករដាំ មានដូចជា: Simung Malato, Marindu, Paspalum, Stylo 184, King Grass, Mimosa។ ខេត្តមួយចំនួន ដែលពាក់ព័ន្ធយ៉ាងសកម្មក្នុងការដាំដំណាំ សម្រាប់ជាចំណីសត្វគឺ កំពុងចាម តាកែវ និងកណ្តាល។

**៣. ឡចំហាយជីវឧស្ម័ន**

នៅប្រទេសកម្ពុជា ប្រជាជនប្រមាណ ៩០% ប្រើធ្យូង លាមកសត្វ និងជីវម៉ាសដទៃទៀតសម្រាប់ចំអិនអាហារ។ ការប្រើប្រាស់អគ្គិសនី ហ្គាស និងប្រេងកាតសម្រាប់ចំអិនមាននៅតែទីក្រុង និងតំបន់ប្រជុំជនប៉ុណ្ណោះ។

រូប១: គ្រោងនៃឡជីវឧស្ម័ន




Source: MAFF, National Biodigester Program, May 2010

1 = អាងផ្ទុកកាកសំណល់ចំរុះ 2 = ទុយោបង្ហូរ 3 = អាងចំហុយ
4 = អាងឧស្ម័ន 5 = ច្រកចូល 6 = អាងចំហា 7 = ទុយោឧស្ម័ន

កម្មវិធីជីវឧស្ម័នជាតិ (**កជជ**) ជាក្រុមហ៊ុនរួមគ្នារវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងភ្នាក់ងារអភិវឌ្ឍហុលឡង់ ដែលមានដំណើរការពី ឆ្នាំ ២០០៦ ដល់ ២០១២។ អ្នកអនុវត្តកម្មវិធីនេះ ជានាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វ។ គោលដៅនៃកម្មវិធីនេះគឺការផ្សព្វផ្សាយ ការប្រើប្រាស់លាមកគោ ក្របី និងជ្រូក ដែលឥឡូវនេះមានសឹងគ្រប់ផ្ទះនៅតំបន់ជនបទ ដើម្បីផលិត ជីវឧស្ម័ន (ម៉េតាន) សម្រាប់ចំអិនអាហារ បំភ្លឺ និងធ្វើជាជីកំប៉ុស។

- **កជជ**ផ្តល់ជំនួយ ចំនួន ១៥០ដុល្លារ ដល់គ្រួសារនិមួយៗ ដើម្បីសហការគ្នាក្នុងការសង់ឡចំហុយជីវឧស្ម័ន (រូប១)។ ក្រៅពីនោះ **កជជ** ជួយឧបត្ថម្ភកសិករដែលត្រូវការថវិកា ដោយធានាប្រាក់កម្ចី ពី ១៥០ ទៅ ១០០០ដុល្លារ ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនពីរ គឺប្រាសាក់ និងអម្រឹត ដោយមានអត្រាការប្រាក់ទាប ១.២% ក្នុង១ខែ។ ទំហំឡដែលគេនិយមគឺមានសមត្ថភាពផលិត៦ម$^{៣}$ ដែលត្រូវចំណាយ ៤៦០ ដុល្លារ។ សព្វថ្ងៃ មានឡចំនួន ៨៤៧៦ កំពុងដំណើរការនៅប្រទេសកម្ពុជា។ ខេត្តដែលមានចំនួនឡច្រើនគឺ តាកែវ (១៩១១ឡ) កំពង់ចាម (១៥២៨) ស្វាយរៀង (១៣៨៣) កំពត (១១៥៣) កំពង់ស្ពឺ (៩១៥) ព្រៃវែង (៤៨៧) កំពង់ឆ្នាំង

(៤៧២)។ គោលដៅចំបងគឺសម្រេចឲ្យបាន ១៨៤០០ឡ នាឆ្នាំ ២០១២។ ផលចំណេញពីឡជីវឧស្ម័នមានច្រើនមុខដូចជា:

- ការសន្សំចំនួន ១២ដុល្លារ /១គ្រួសារ /១ខែ ពីការទិញអុស ធ្យូង និងប្រេងកាត
- ការកាត់បន្ថយអុស ដោយសន្មតថា គ្រួសារនីមួយៗប្រើអុស ៦គក្រ /១ថ្ងៃ
- ការកាត់បន្ថយឥទ្ធិពលលើបរិស្ថាន
- ការធ្វើជីកំប៉ុសពីកាកសំណល់ដែលបានពីឡជីវឧស្ម័ន គឺសំបូរទៅដោយសារជាតិ N, P, K សម្រាប់ប្រើដាក់ស្រែ
- ការសន្សំពេលចំនួន ២ម៉ោង/១ថ្ងៃ របស់ស្ត្រី និងកុមារពីការដើររកអុស។

**តារាង ៦. ទំហំឡ ធាតុចូល និងធាតុចេញឧស្ម័ន**

| ទំហំឡ ម៣ | 4 | 6 | 8 | 10 | 15 |
|---|---|---|---|---|---|
| បរិមាណលាមកសត្វ (គក្រ): ធាតុចូលដំបូង | 1,500 | 2,300 | 3,000 | 3,800 | 6,000 |
| ធាតុចូលបន្ថែមប្រចាំថ្ងៃ (គក្រ) | 20-40 | 40-60 | 60-80 | 80-100 | 100-150 |
| បរិមាណទឹកបន្ថែម (លីត្រ) | 20-40 | 40-60 | 60-80 | 80-100 | 100-150 |
| ថាមពលផលិតបានសម្រាប់ចង្ក្រានហ្គាស (ម៉ោង) | 2-4 | 4-6 | 6-8 | 8-10 | 10-15 |
| ថាមពលផលិតបានសម្រាប់អំពូលភ្លើង (ម៉ោង) | 8-16 | 16-24 | 24-32 | 32-40 | 40-60 |

សន្មត:

- មេគោមួយ ផលិតបានលាមក ៨.៣ គក្រ /១ថ្ងៃ ក្របី ១២.៤ គក្រ /១ថ្ងៃ ជ្រូក ១.៥ គក្រ /១ថ្ងៃ
- ចង្ក្រានហ្គាសប្រើហ្គាស ៤០០លីត្រ/១ម៉ោង
- អំពូលភ្លើងហ្គាសប្រើហ្គាស ១០០លីត្រ/១ម៉ោង
- ជាមធ្យម ១គក្រលាមកសត្វ ផលិតឧស្ម័នបាន ៤០លីត្រ

Source: MAFF, National Biodigester Program, May 2010

តារាង៦ ខាងលើបង្ហាញទំហំឡ ធាតុចូលលាមកសត្វ និងថាមពលដែលផលិតបាន បន្ទាប់ពី ៤០ថ្ងៃនៃការចំហុយ។

### ៤. ការការពារសុខភាពសត្វ ការចាក់វ៉ាក់សាំង និងការព្យាបាល

ទាក់ទងនឹងសុខភាពសាធារណ: និងសត្វ នាយកដ្ឋានបសុព្យបាល និងផលិតកម្មសត្វ បានធ្វើសកម្មភាពរួមមាន ការពិនិត្យ ចាក់វ៉ាក់សាំង ព្យាបាល សត្វឈឺ និងចែកចាយពត៌មាន ដើម្បីអប់រំសាធារណ:។ តារាង៧ បង្ហាញបញ្ជីគ្រូតពិនិត្យសុខភាពសត្វឆ្នាំ ២០០៩។

តារាង ៧: បញ្ជីត្រួតពិនិត្យសុខភាពសត្វឆ្នាំ ២០០៩ (ក្បាល)

| ប្រភេទសត្វ | ចំនួន |
|---|---|
| ស្វា | 10,740 |
| គោក្របី | 60,670 |
| កូនជ្រូក | 12,500 |
| មេជ្រូកពូជ | 10,782 |
| បាជ្រូកពូជ | 510 |
| ជ្រូកយកសាច់ | 43,500 |

Source: MAFF, Annual Report 2009

តារាង៨ បង្ហាញចំនួនការចាក់វ៉ាក់សាំងសត្វតាមប្រភេទជំងឺ ពីឆ្នាំ ២០០៧ ដល់ ២០០៩ និងតារាង ៩ បង្ហាញចំនួនសត្វឈឺ ការព្យាបាលសត្វ និងសត្វស្លាប់ដោយសារជំងឺ។

តារាង ៨: ការពិនិត្យសុខភាពសត្វ និងការចាក់វ៉ាក់សាំង ប្រចាំឆ្នាំ

| ជំងឺ | 2007 | 2008 | 2009 |
|---|---|---|---|
| ជំងឺបូសខ្យល់គោ | 9,581 | 5,836 | 3,004 |
| ជំងឺបូសខ្យល់ក្របី | 1,729 | 409 | 405 |
| ជំងឺសារទឹកគោ | 1,664,826 | 1,327,678 | 1,200,899 |
| ជំងឺសារទឹកក្របី | 376,055 | 279,812 | 324,141 |
| ជំងឺអុតក្ដាមគោ | 21,546 | 25,773 | 31,771 |
| ជំងឺអុតក្ដាមក្របី | 2,812 | 1,613 | 11,123 |
| ជំងឺឈាមខ្មៅគោ | 1,264 | 0 | 0 |
| ជំងឺឈាមខ្មៅក្របី | 145 | 0 | 0 |
| ជំងឺសារទឹកជ្រូក | 92,933 | 76,893 | 125,796 |
| ជំងឺអាសន្នរោគជ្រូក | 205,168 | 154,547 | 143,094 |
| ជំងឺជ្រូកពុល (Salmonellosis) | 63,353 | 87,334 | 2,440 |
| ជំងឺអុតក្ដាមជ្រូក | 13,071 | 46,727 | 0 |
| ជំងឺអុតមាន់ | 99,850 | 67,549 | 78,104 |
| ជំងឺ Newcastle | 500,105 | 246,462 | 278,457 |
| ជំងឺអាសន្នរោគបក្សី | 289,649 | 154,002 | 195,689 |

Source: Department of Animal Health & Production, Annual Report 2007, 2008, 2009.

តារាង ៩: ចំនួនសត្វឈឺ សត្វបានព្យាបាល និងសត្វស្លាប់ពីជំងឺ (ក្បាល)

| ប្រភេទសត្វ | 2007 | 2009 |
|---|---|---|
| គោក្របីឈឺ | N/A | 106,755 |
| គោក្របីបានព្យាបាល | 69,150 | 79,865 |
| គោក្របីឈឺងាប់ | 2,760 | 2,388 |
| ជ្រូកឈឺ | N/A | 135,103 |
| ជ្រូកបានព្យាបាល | 165,280 | 124,806 |
| ជ្រូកងាប់ | 8,600 | 15,140 |
| បក្សីងាប់ (ជាង ៩០% ជាមាន់) | 38,189 | N/A |

Source: Department of Animal Health & Production, Annual Report 2007, 2009.

មានការប្រឹងប្រែងលើការបណ្តុះបណ្តាលបុគ្គលិក អ្នកភូមិ និងអ្នកបច្ចេកទេសដែលជាពេទ្យសត្វ ជាមួយនឹងការបែងចែកព័ត៌មានបច្ចេកទេសនៃការចិញ្ចឹមសត្វ ការគាំពារជំងឺ និងការព្យាបាល និងពត៌មានទីផ្សារអំពីផលិតផលរបស់ពួកគេ។ ការប្រឹងប្រែងទាំងអស់នេះទទួលបាននូវជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសពីអង្គការអន្តរជាតិនានា និងរាជរដ្ឋាភិបាល បន្ថែមលើថវិកាជាតិ។ ទោះបីយ៉ាងណាក្តី ជំនួយហិរញ្ញវត្ថុនៅមិនទាន់គ្រប់គ្រាន់ ដែលឆ្លុះបញ្ចាំងដោយចំនួនយ៉ាងច្រើននៃសត្វស្លាប់។

## III. ការប្រឈម និងដែនកំណត់

នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វ បានបញ្ចេញនូវការប្រឹងប្រែងជាច្រើន និងគួបផ្សំនឹងឆន្ទៈ និងសហប្រតិបត្តការពីដៃគូអន្តរជាតិ ដើម្បីអភិវឌ្ឍវិស័យចិញ្ចឹមសត្វក្នុងប្រទេសកម្ពុជា។ ទោះបីដូច្នេះក៏ដោយ ក៏វិស័យនេះនៅតែជួបប្រទះនឹងឧបសគ្គជាច្រើនដែលរំខានដល់នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វក្នុងការសម្រេចគោលដៅដូចជា:

១. ការខ្វះមូលនិធិសម្រាប់ធ្វើការស្រាវជ្រាវ ការចាក់វ៉ាក់សាំង និងការព្យាបាលសត្វ

២. សេវាមិនគ្រប់គ្រាន់ផ្តល់ដោយអាជ្ញាធរកសិកម្ម ក្នុងការចែកចាយព័ត៌មានអំពីបច្ចេកទេសចិញ្ចឹមគោ ការតាមដាន ការគាំពារនិងព្យាបាលជំងឺ និងព័ត៌មានទីផ្សារដល់អ្នកចិញ្ចឹមគោ។ ជាលទ្ធផលនៃកង្វះនេះ ការយល់ដឹងរបស់អ្នកចិញ្ចឹមសត្វក៏មានកំរិតតិចតួច អំពីការចិញ្ចឹម សុខភាព និងបញ្ហាទីផ្សារ។

៣. អត្រាខ្ពស់នៃសត្វឈឺ នឹងការស្លាប់របស់សត្វ

៤. ការផ្គត់ផ្គង់មិនគ្រប់គ្រាន់នៃចំណីសត្វ ជាបរិមាណ នឹងគុណភាព

៥. ការខ្វះភាពចម្រុះនៃពូជសម្រាប់បង្កាត់

៦. ជំនួយហិរញ្ញវត្ថុមិនគ្រាប់គ្រាន់

៧. សូចនាករទូទៅ នៃការនាំចេញនៅមានកំរិតទាប មួយចំណែកដោយសារជំងឺ និងការតម្រូវឯកសារអនាម័យរបស់ប្រទេសនាំចូល។

## IV. **កាលានុវត្តភាព**

នៅពេលដែលការចិញ្ចឹមគោ ក្របី ជ្រូក និងបក្សី ប្រមូលផ្តុំតែលើដែកសិករខ្នាតតូច ដែលបង្ហាញខិនភាពក្នុងការអភិវឌ្ឍ ការចិញ្ចឹមនេះក៏ដើតួជាសញ្ញាសក្តានុពល សម្រាប់អភិវឌ្ឍបន្ត តាមរយៈសកម្មភាពត្រឹមត្រូវ ធនធានដែលមាន និងការចាប់យកឱកាសត្រូវ។

១. **ជំនួយថវិកាពរដ្ឋាភិបាល:** គំរោងហេដ្ឋារចនាសម្ព័ន្ធជាច្រើន បានធ្វើឡើង និងសង្ឃឹមថាឆាប់ៗនេះ រដ្ឋអាចបញ្ចេញមូលធនមួយចំនួនដើម្បីជួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមទាំងនាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វ ក្នុងការបំពេញមុខងាររបស់ខ្លួនឲ្យបានប្រសិទ្ធភាព។ ជាមួយនឹងមូលនិធិគ្រប់គ្រាន់ នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វអាចបង្កើនការចិញ្ចឹម ការគាំពារ ការព្យាបាល ក្នុងករណីមានការកើតឡើងនូវជំងឺ និងកម្មវិធីផ្សេងៗទៀតដើម្បីផ្តល់ជាសេវាល្អៗដល់អ្នកចិញ្ចឹមសត្វ។

២. **សក្តានុពលទីផ្សារ:** មានសក្តានុពលទីផ្សារបសុសត្វយ៉ាងធំសម្រាប់កម្ពុជា ក្នុងតំបន់ និងអាស៊ីកណ្តាល។ លក្ខខ័ណ្ឌពាណិជ្ជកម្មពីភពលោកនៃបសុសត្វមានលក្ខណៈចំហ ក្នុងន័យអគ្រាពន្ធទាប និងការតម្រូវនៃអនាម័យ។ តម្រូវការសាច់សត្វនៅក្នុងប្រទេសកំពុងរីកចំរើន ត្រូវបានប៉ាន់ស្មានថានឹងមានកំរិតឡើងជាលំដាប់។ ឧទាហរណ៍មានការឡើង៣%ក្នុង១ឆ្នាំ នៅតំបន់អាស៊ីអគ្នេយ៍ និងប្រទេសចិនក្នុងកំលុងឆ្នាំ១៩៩៣ដល់២០២០។ នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វ ដើរតួរជាមជ្ឈមណ្ឌលទំនាក់ទំនងការិយាល័យអន្តរជាតិពិនិត្យជំងឺរាតត្បាតសត្វ (Office International des Epizooties: OIE) សម្រាប់សុខភាពសត្វនៅកម្ពុជា។ វិទ្យាស្ថានប៉ាស្ទ័រ ទទួលខុសត្រូវលើការធ្វើតេស្តសុខភាពសត្វសឹងតែទាំងអស់ជំនួស នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វ ។ នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វ ទទួលខុសត្រូវតែរឿងពិនិត្យសត្វ និងផលិតផលពីសត្វនាំចេញពីកម្ពុជា និងការចេញវិញ្ញាបណ្ណបត្រសុខភាពសត្វ ដែលតម្រូវដោយការិយាល័យអន្តរជាតិពិនិត្យជំងឺរាតត្បាតសត្វ។ ដំណើរការនេះអាចបង្កើនផលិតផលសត្វ និងការនាំចេញ ពីកម្ពុជា។

៣. បង្កើនសមត្ថភាពអ្នកចិញ្ចឹមបសុសត្វ និងសហគ្រិន: អាចពង្រឹងខ្សែចង្វាក់ផ្គត់ផ្គង់ និងអាចប្រមូលផ្តុំទៅជាសមាគមបសុសត្វ និងបក្សី។

៤. កាលានុវត្តភាពនៃភាពជាដៃគូរដ្ឋ–ឯកជន មានអត្ថិភាព និងអាចចងភ្ជាប់ទៅនឹងការអភិវឌ្ឍឧស្សាហកម្មទឹកដោះ និងស្បែក ជាពិសេស ក្នុងខេត្តកណ្តាល និងតំបន់ក្បែរទីប្រជុំជន ដែលអាចផ្តល់ឪកាសការងារដល់តំបន់ជនបទ។

៥. បន្តអភិវឌ្ឍភាពជាដៃគូ ជាមួយឯកជន អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល អាចជួយជំរុញការឧបត្ថមបច្ចេកទេស និងហិរញ្ញវត្ថុដល់អ្នកចិញ្ចឹមសត្វ និងមាន់ទា។

៦. ធនធានដីនៅសំបូរបង្គួរនៅឡើយ សម្រាប់អ្នកចិញ្ចឹមគោ។

## V. **អនុសាសន៍**

ការប្រឈម និងដែនកំណត់ដែលចែងខាងលើ អាចជំនះបាននៅពេលដែល មានវិធានការមួយចំនួនដូចខាងក្រោមៈ

១. ផ្តល់មូលនិធិគ្រប់គ្រាន់ដល់នាយកដ្ឋានបសុព្យាបាល និងផលិតកម្មសត្វ ដើម្បីពង្រឹងៈ

–ផលិតផលសត្វ ដោយប្រើពូជបង្កាត់ល្អៗ

– ការត្រួតពិនិត្យ និងគ្រប់គ្រងសត្វ និងសាច់

– ការចាក់វ៉ាក់សាំង ព្យាបាល និងគាំពារក្នុងករណីមានជំងឺឆ្លង

– ភាពចងទំនាក់ទំនងនៃសកម្មភាពតាមរយៈខ្សែចង្វាក់ផ្គត់ផ្គង់សាច់ បង្កាត់ពូជរយៈពេលខ្លី ការធានាការផ្គត់ផ្គង់ចំណីសត្វ ការព្យាបាល និងការកែច្នៃវត្ថុពីសត្វ (ស្បែក ស្នែង ទឹកដោះ)។

២. ការលើកទឹកចិត្តគួរផ្តល់ឲ្យក្រុមហ៊ុនឯកជន សម្រាប់ការចាប់ផ្តើមធុរកិច្ចទ្រង់ទ្រាយធំ សម្រាប់ផលិតផល គោ ក្របី ជ្រូក បក្សី ពីព្រោះភាពខ្សោយនៃវិនិយោគសាធារណៈលើវិស័យនេះ។

## VI. **សេចក្តីសន្និដ្ឋាន**

ដោយដឹងថា នាពេលបច្ចុប្បន្ននេះ មាន គ្រួសារ១.៧លានរួចមកហើយ ដែលចិញ្ចឹមបសុសត្វ ដូច្នេះវាមិនពិបាកទេ ក្នុងការបង្កើនចំនួនបសុសត្វ ដើម្បីផ្គាប់ការប្រើប្រាស់ក្នុងស្រុកក៏ដូចជាការនាំចេញ។ អ្វីដែលជាតម្រូវការចាំបាច់ឥឡូវគឺការកែលំអស្តង់ដាពេទ្យសត្វ និងវិធានការគ្រប់គ្រង និងកំចាត់ជំងឺសត្វផ្សេងៗ៕

14/Nov/'01

**បណ្ឌិត ស៊ិន ម៉េងស្រ៊ុន**
**ប្រធានអនុក្រុមកសិកម្ម**
**កសខ**

## ឯកសារយោង

Cambodian Development Research Institute (CDRI), (2006 - 2009), Annual Development Review, 2006, 2007, 2008, 2009
FAO (2010), National Gender Profile of Agricultural Households
Hang Chuon Naron (2009), Cambodian Economy: Charting the Course of a Brighter Future.
Korean Development Institute (KDI), (2004), Enhancing Development Competence of Cambodia
MAFF (2007 - 2009), Directorate of Animal Health and Production Annual Report 2007, 2008, 2009
MAFF (2010), National Biodigester Program (NBP)
Ministry of Commerce, (1996), Cambodia Business and Investment Handbook
Ministry of Commerce, (2007), Cambodia 's Updated Trade Integration Strategy (DTIS) 2007
MAFF, (2009), Annual Report
National Institute of Statistics, (2008), Statistical Yearbook of Cambodia
Royal Government of Cambodia, (2002), Second Five Year Socio-economic Development Plan 2001 – 2005
Suon Sothoern, (2003), Domesticated Animal Genetic Resources in Cambodia
USAID, (2009), Achieving Food Security in Cambodia Through Improved Agriculture and Environmental Sustainability

## ការសំភាសន៍

Dr. Suon Sothoeun, Deputy Director, Directorate of Animal Health and Production, on September 26, 2010